# រូបិយវត្ថុកម្ពុជា



ប្រភេទក្រដាសប្រាក់: ៥០រៀល
ទំហំ: ១៣០មម x ៦០មម
ឆ្នាំបោះពុម្ព: ២០០២
ពណ៌ផ្ទៃ: លឿងទុំ
ពណ៌នា: ផ្នែកកណ្តាលនៃក្រដាសប្រាក់រំលេចឡើងនូវរូបក្លោងទ្វារប្រាសាទបន្ទាយស្រី។ ផ្នែកខាងស្តាំមានរូបនរៈសិង្ហ នឹងផ្នែកខាងឆ្វេងមានរូបចម្លាក់ក្បាលនាគ។



ប្រភេទក្រដាសប្រាក់: ១០០រៀល
ទំហំ: ១៣០មម x ៦០មម
ឆ្នាំបោះពុម្ព: ២០០១
ពណ៌ផ្ទៃ: ស្វាយ និងបៃតង
ពណ៌នា: រំលេចឡើងនូវទិដ្ឋភាពនៃសាលារៀនមួយខ្នង និងសិស្សានុសិស្សកំពុងដើរសំដៅទៅកាន់ថ្នាក់រៀនរបស់ខ្លួន។



ប្រភេទក្រដាសប្រាក់: ៥០០រៀល
ទំហំ: ១៣៨មម x ៦៤មម
ឆ្នាំបោះពុម្ព: ២០០៣
ពណ៌ផ្ទៃ: ក្រហម
ពណ៌នា: រូបភាពស្ពានគីស៊្ហិណា "កម្ពុជា-ជប៉ុនដែលឆ្លងកាត់ទន្លេមេគង្គ ស្ថិតក្នុងទីរួមខេត្តកំពុងចាម។



ប្រភេទក្រដាសប្រាក់: ១០០០រៀល
ទំហំ: ១៣៨មម x ៦៤មម
ឆ្នាំបោះពុម្ព: ២០០៦
ពណ៌ផ្ទៃ: ឈាមជ្រូក និងខៀវ
ពណ៌នា: រូបភាពកំពង់ផែខេត្តព្រះសីហនុ ដែលកំពុងមានសកម្មភាពមមាញឹកក្នុងការលើកដាក់ទំនិញ។



ប្រភេទក្រដាសប្រាក់: ២០០០រៀល
ទំហំ: ១៤៦មម x ៦៨មម
ឆ្នាំបោះពុម្ព: ២០០៨
ពណ៌ផ្ទៃ: បៃតងក្រមៅ និងលឿង
ពណ៌នា: រូបទ្វារប្រាសាទព្រះវិហារ និងអក្សរ "ពីរពាន់រៀល" នៅពីខាងក្រោម។



ប្រភេទក្រដាសប្រាក់: ៥០០០រៀល
ទំហំ: ១៤៦មម x ៦៨មម
ឆ្នាំបោះពុម្ព: ២០០១
ពណ៌ផ្ទៃ: ប្រផេះ និងបៃតង
ពណ៌នា: រូបស្ពានបុរាណនៅកំពង់ក្តី ខេត្តសៀមរាប។



ប្រភេទក្រដាសប្រាក់: ១០០០០រៀល
ទំហំ: ១៤៦មម x ៦៨មម
ឆ្នាំបោះពុម្ព: ២០០១
ពណ៌ផ្ទៃ: ពណ៌ស្វាយ ពណ៌ត្នោត និងខៀវ
ពណ៌នា: រូបភាពពិធីបុណ្យអុំទូកនៅមុខព្រះបរមរាជវាំង។



ប្រភេទក្រដាសប្រាក់: ២០០០០រៀល
ទំហំ: ១៥០មម x ៧០មម
ឆ្នាំបោះពុម្ព: ២០០៨
ពណ៌ផ្ទៃ: ស៊ីជម្ពូ និងពណ៌ខៀវ
ពណ៌នា: រូបភាពប្រាសាទអង្គរធំទាំងមូលមើលបញ្ឆិតពីលើ និងរូបចម្លាក់ព្រហ្មមុខបួននៃប្រាសាទបាយ័ន។



ប្រភេទក្រដាសប្រាក់: ៥០០០០រៀល
ទំហំ: ១៥០មម x ៧០មម
ឆ្នាំបោះពុម្ព: ២០០១
ពណ៌ផ្ទៃ: លឿង ឈាមជ្រូក និងត្នោត
ពណ៌នា: រូបភាពប្រាសាទអង្គរវត្ត មើលបញ្ឆិតពីលើ។